20/3

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍
សំណុំរឿងរដ្ឋប្បវេណី
លេខ ៥២៨/២៨-១១-២០១១

សាលដីកា
លេខ ០២ ក្រ.III "ណ" /០១-៣-១២

# តាងនាមប្រជារាស្ត្រខ្មែរ
## សាលាឧទ្ធរណ៍

បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ នៅថ្ងៃទី ១៤-០២-២០១២ ។

ក្រុមប្រឹក្សាជំនុំជម្រះ

លោក [redacted] ជាប្រធាន
លោក [redacted] ជាចៅក្រមប្រឹក្សា
លោកស្រី [redacted] ជាចៅក្រមប្រឹក្សា

ក្រឡាបញ្ជីសវនាការ

លោក ទី ចិត្តត្រា

-ដើមចោទឈ្មោះ [redacted] សួន ភេទប្រុស អាយុ ៤៩ ឆ្នាំ ជាតិខ្មែរ មុខរបរគ្រូបង្រៀន មានទីលំនៅភូមិត្រពាំងរុន ឃុំកន្ទោរមអក ស្រុកកំពង់ត្របែក ខេត្តព្រៃវែង (ចុងបណ្តឹងឧទ្ធរណ៍)។

-ចុងចម្លើយឈ្មោះ [redacted] ធន់ ភេទប្រុស អាយុ ៤៩ ឆ្នាំ ជាតិខ្មែរ មុខរបរគ្រូបង្រៀន មានទីលំនៅភូមិកន្ទោរមអក ឃុំកន្ទោរមអក ស្រុកកំពង់ត្របែក ខេត្តព្រៃវែង ប្រពន្ធឈ្មោះ [redacted] ដានី (ដើមបណ្តឹងឧទ្ធរណ៍)។

ខ្លឹមសារនៃសាលក្រមដែលដើមចោទប្តឹងទាមទារ ៖

-សុំទាមទារប្រាក់ជំពាក់ចំនួន ៨.១៥០.០០០ រៀល

-សុំទាមទារសោហ៊ុយបង់ខាតចំនួន ២.០០០.០០០ រៀល

### អង្គហេតុ និងចំណុចវិវាទ ៖

តាមពាក្យបណ្តឹង ចុះថ្ងៃទី ៣០-១២-២០១០ របស់ដើមចោទឈ្មោះ [redacted] សួន បញ្ជាក់ថា ចុងចម្លើយឈ្មោះ [redacted] ធន់ និងប្រពន្ធឈ្មោះ [redacted] ដានី បានពឹងខ្លួនឲ្យរកប្រាក់គេឲ្យ និងបានលេងតុងទីនជាមួយខ្លួន ហើយបានជំពាក់ប្រាក់ខ្លួនសរុបចំនួន ៨.១៥០.០០០ រៀល មិនព្រមសង ។

នៅថ្ងៃទី ១៣-១២-២០១០ ឈ្មោះ [redacted] ធន់ បានមកធ្វើកិច្ចសន្យាទទួលស្គាល់ថា ពិតជាជំពាក់ខ្លួនចំនួន ៨.១៥០.០០០ រៀល ប្រាកដមែន តែក្រោយមកពេលខ្លួនទៅទារប្រាក់ពីប្តី-ប្រពន្ធនេះ ស្រាប់តែប្រកែកមិនព្រមសង ហើយនិយាយថា ចង់ប្តឹងឯណាប្តឹងទៅ ទើបខ្លួនដាក់ពាក្យចូលមកតុលាការសុំប្តឹងទាមទារប្រាក់ជំពាក់ចំនួន ៨.១៥០.០០០ រៀល និងជំងឺចិត្ត ព្រមទាំងការខាតបង់ពេលវេលាចំនួន ២.០០០.០០០ រៀល ។

១២៨ 128

Scanned with CamScanner

## ការអះអាងរបស់គាគីដើមចោទ

-ឈ្មោះ [redacted] សួន អះអាងថា ចុងចម្លើយបានលេងតុងទីនចំនួន ៤ ក្បាល, ខ្លួនមិនព្រមឲ្យលេងដែរ តែគាត់អះអាងថា មានលទ្ធភាពបង់ ព្រោះគាត់មានប្រាក់ខែទាំងប្តីទាំងប្រពន្ធ មិនមែនតែប្រាក់តុងទីនប៉ុណ្ណោះទេ គឺចុងចម្លើយបានខ្ចីប្រាក់ខ្លួនទៀត ដោយខ្លួនពុំមានប្រាក់ផ្ទាល់ខ្លួនឲ្យខ្លួនបានទៅធានាប្រាក់គេឲ្យ ពេលចុងចម្លើយមិនព្រមសង គឺខ្លួនជាអ្នកទទួលខុសត្រូវទាំងស្រុង។

ចុងចម្លើយមិនព្រមសងប្រាក់ឲ្យខ្លួនហើយ ហើយបានជំរុញឲ្យខ្លួនទៅប្តឹងទៀត ។ ខ្លួនមិនយល់ព្រមតាមការសុំសងរបស់ចុងចម្លើយក្នុង ១ ខែ សងចំនួន ១៥០.០០០ រៀល នោះទេ គឺខ្លួនសុំឲ្យសងគ្រប់ចំនួនតែម្តង ។

## ការអះអាងរបស់គាគីចុងចម្លើយ

-ឈ្មោះ [redacted] ធន់ អះអាងថា ខ្លួនត្រូវជាប្តីរបស់ឈ្មោះ [redacted] ដានី ហើយចំពោះប្រាក់ដែលខ្លួនជំពាក់ដើមចោទនោះ គឺពីដំបូងជាប្រាក់លេងតុងទីនទេ ។ ខ្លួនទទួលស្គាល់ថា ពិតជាជំពាក់ប្រាក់ដើមចោទប្រាកដមែន ហើយកន្លងមកខ្លួនបានសងគាត់ខ្លះហើយ ។ នៅពេលនេះ ខ្លួនមិនមានលទ្ធភាពសងគ្រប់ចំនួនទេ ដោយសុំសងក្នុងមួយខែចំនួន ១៥០.០០០ រៀល ព្រោះប្រាក់ខែរបស់ខ្លួន និងប្រពន្ធតិចតួច ។

## សំអាងហេតុ

### សាលាឧទ្ធរណ៍យល់ឃើញថា ៖

១-ពាក្យបណ្តឹងឧទ្ធរណ៍លេខ ១៧ ចុះថ្ងៃទី ១៧-៦-២០១១ របស់ឈ្មោះ [redacted] ធន់ ប្តឹងឧទ្ធរណ៍នឹងសាលក្រមរដ្ឋប្បវេណីលេខ ១០ "ឆ" រ.វ ចុះថ្ងៃទី ១៩-៥-២០១១ របស់សាលាដំបូងខេត្តព្រៃវែង ធ្វើឡើងក្នុងកំណត់ច្បាប់ ដែលអាចឲ្យសាលាឧទ្ធរណ៍ធ្វើការទាញហេតុផលដោយផ្ទាល់មាត់បាន ផ្អែកតាមមាត្រា ២៦០ និងមាត្រា ២៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

២-ផ្អែកតាមសេចក្តីថ្លែងការណ៍របស់ឈ្មោះ [redacted] ធន់ បានសារភាពថា ខ្លួនពិតជាបានជំពាក់ប្រាក់តុងទីន តាមកិច្ចសន្យាចុះថ្ងៃទី ១៣-១២-២០១០ ប្រាកដមែន ។ ចំពោះប្រាក់ជំពាក់នេះ ខ្លួនសុំសងមួយខែចំនួន ១៥០.០០០ រៀល ។

៣-សំអាងហេតុ និងសេចក្តីសម្រេចក្នុងសាលក្រមរដ្ឋប្បវេណីលេខ ១០ "ឆ" រ.វ ចុះថ្ងៃទី ១៩-៥-១១ របស់សាលាដំបូងខេត្តព្រៃវែង មានមូលហេតុត្រឹមត្រូវតាមច្បាប់ គប្បីសាលាឧទ្ធរណ៍ចេញសាលដីកាតម្កល់សាលក្រមនេះ ទុកជាបានការ ។

## ហេតុដូច្នេះ

## វិនិច្ឆ័យសេចក្តី ៖

១-ច្រានពាក្យបណ្តឹងឧទ្ធរណ៍លេខ ១៧ ចុះថ្ងៃទី ១៧-៦-២០១១ របស់ឈ្មោះ [redacted] ធន់ ចោលជាអសារបង់ ។

២-តម្កល់សាលក្រមរដ្ឋប្បវេណីលេខ ១០ "ឆ" រ.វ ចុះថ្ងៃទី ១៩-៥-២០១១ របស់សាលាដំបូងខេត្តព្រៃវែង ទុកជាបានការ ។

៣-ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ឈ្មោះ [redacted] ធន់ ។

១៥៥១

Scanned with CamScanner

៨-សាលដីកានេះ ធ្វើការទាញហេតុផលដោយផ្ទាល់មាត់ នៅថ្ងៃទី ១៥-០២-២០១២ និង ប្រកាសជាសាធារណៈ នៅថ្ងៃទី ០១-៣-២០១២ ។

| | | |
|---|---|---|
| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុះជម្រះ |

ហត្ថលេខា [redacted]

---

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ភ្នំពេញ ថ្ងៃទី ១២ ខែ ៧ ឆ្នាំ ២០១២

| | |
|---|---|
| បានឃើញ | ក្រឡាបញ្ជី |
| ប្រធានក្រុមប្រឹក្សា | |
| [redacted] | [redacted] |



Scanned with CamScanner